អង្គការសាលារៀនឧទ្យាយ

របាយការណ៍ប្រចាំឆ្នាំ ២០២២



អាសយដ្ឋាន៖ អគារលេខ ៨១៧ វិថី១៩៥២ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទទំនាក់ទំនង៖ ០១២៣៦៩៣៧៦

អ៊ីម៉ែល៖ huntouch40@gmail.com

គេហទំព័រ៖ www.rabbitschoolcambodia.net.

Content

អក្សរកាត់.....3

១របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ២០២២ 4

២របាយណ៍សង្ខេប 6

៣ឧបសគ្គ 11

៤ យុទ្ធសាស្ត្រ .និងផែនការបន្ទាប់ 12

៥ឧបសម្ព័ន្ធ៖ រូបភាពសកម្មភាពផ្សេងៗ 13


៦ករណីសិក្សា 18

អក្សរកាត់


Acronyms/Abbreviations	Full words
CRS	Catholic Relief Service
EPC	Essential Personal Center
HI	Human Inclusion
DDP	Deaf Development Program
PPCIL	Phnom Penh Center for Independent Living - PPCIL
RTI	Research Triangle Institute
NISE	National Institute for Special Education
NEP	NGO Education Partnership
NEA	National Employment Agency
GMAC	Garment Manufacturers Association in Cambodia
HHC	Hand of Hope Community

១. រចាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ២០២២

ចំណូលពីថ្នាស់ជំនួយ	ចំនួន
អេដ អេអាក់ស្យុងកម្ពុជា	$ 101,635.06
មូលនិធិកុមារកម្ពុជា	$ 20,000.00
មជ្ឈមណ្ឌលស្រាវជ្រាវ RCI	$ 17,001.49
ចំណូលផ្សេង	$ 11,393.14
បដិភាគអាណាព្យាបាល	$ 15,493.51
សកម្មភាពប្រជាជនសម្រាប់ការអភិវឌ្ឍន៍រួម	$ 18,248.00
ធីសីដីអេ	$ 4,052.00
អ៊ុកស្វាម កម្ពុជា	$ 4,405.27
សរុប	$192,228.47



ចំណាយ	ចំនួន
ធនធានមនុស្ស	$ 69,074.04
ការធ្វើដំណើរ	$ 1,879.44
ឧបករណ៍និងសំភារៈផ្គត់ផ្គង់	$ 251.50
គ្រឿងបរិក្ខារក្នុងស្រុក	$ 5,554.82
ចំណាយលើសកម្មភាព	$ 131,364.68
សរុប	$208,124.48



២. វេចខ្ចប់ឯកសារ

លទ្ធផលទី ១៖ កុមារក្រៅសាលាបានទទួលឱកាសចូលរៀនកម្រិតបឋមប្រសើរឡើងប្រកបដោយសមធម៌។

ការជុសជុលថ្នាក់អប់រំបរិយាប័ន្ន រួមមានបង្គន់ ជម្រាល និងបន្ទប់ថ្នាក់បរិយាប័ន្ននៅសាលាគោលដៅ

ជម្រាបចំនួន ១៤ និងបង្គន់អនាម័យចំនួន ៥ ត្រូវបានជុសជុលកែលំអរនៅតាមសាលាគោលដៅចំនួន ១០ (នៅអង្គស្នួល ២ កណ្តាលស្នឹង ៧ ច្បារមន ២ សំរោងទង ២ និងពួក ៦)។

ការជុសជុលអាគារ និងបណ្ណាល័យឌីជីថលនៅសាលាបឋមសិក្សាទួលគោក

បណ្ណាល័យឌីជីថលចំនួន១ ត្រូវបានរៀបចំឡើងដោយមានបំពាក់សម្ភារ និងប្រដាប់ប្រដាក្មេងលេងមួយចំនួននៅសាលាបឋមសិក្សាទួលគោក។ សម្ភារៈទាំងនោះរួមមាន ទូរទស្សន៍ឆ្លាតវៃ និងឧបករណ៍បំពងសម្លេង កៅអី កុំព្យូទ័រ ក្តារខៀន តុ ទូរចល័តវែង ការតភ្ជាប់អ៊ីនធឺណិត ស្មៅប្លាស្ទិក ប្រដាប់ក្មេងលេង សៀវភៅរូបថត សៀវភៅគ្រូ កៅអី ទូរ ភ្លើង កង្ហារ។ល។

ជំណើរការថ្នាក់សមាហរណកម្ម ៥៤ថ្នាក់សម្រាប់កុមារមានពិការភាពសតិបញ្ញា

ថ្នាក់សមាហរណកម្មចំនួន ៤៦បន្ទប់ ត្រូវបានបង្កើតឡើង និងដំណើរការសម្រាប់កុមារមានពិការភាពសតិបញ្ញា។ ការសមិទ្ធផលសម្រេចបានមានចំនួនតិចជាងផែនការ ដោយសារខ្វះគ្រូអប់រំពិសេស។ អង្គការសាលារៀនទន្សាយ បានផ្តល់សម្ភារៈបង្រៀនដល់ថ្នាក់សមាហរណកម្មចំនួន ២៣ ដូចជា ម៉ាស៊ីនអ៊ុតចំនួន 1គ្រឿង ក្រដាស A៣ ចំនួន ២ រ៉ាម ម្ជុលដោតចំនួន ២ដុំ ជក់ចំនួន ២៣ សម្ភារៈសម្រាប់ជូតសម្អាតឥដ្ឋចំនួន ២៣ សាប៊ូទឹកលាងសម្អាតបង្គន់ចំនួន ២៣ ថង់ប្លាស្ទិកចំនួន ៣៤.៥ គីឡូក្រាម។

ការគាំទ្រថ្នាក់អប់រំបរិយាប័ន្ន តាមរយៈការផ្តល់សម្ភារសិក្សា និងជំនួយការបង្រៀន និងឧបករណ៍ជំនួយផ្សេងទៀតដល់ថ្នាក់អប់រំបរិយាប័ន្ន

ថ្នាក់អប់រំបរិយាប័ន្នចំនួន ៣៦ថ្នាក់ (៥ នៅអង្គស្នួល ៨ នៅកណ្តាលស្នឹង ៩ នៅសំរោងទង ៦ នៅស្រុកច្បារមន និង ៨ នៅស្រុកពួក) ត្រូវបានបង្កើតឡើង និងផ្តល់សម្ភារសិក្សា និងសម្ភារបង្រៀន ដូចជា ប័ណ្ណព្យញ្ជនៈ ប័ណ្ណលេខ ល្បែងផ្គុំរូប ប័ណ្ណរូបភាព សៀវភៅគំនូរ ផ្ទាំងរូបភាពគណិតវិទ្យា សៀវភៅនិទានរឿង ប្រដាប់ប្រដារៀនផ្សេងៗ។ល។ លទ្ធផលគឺតិចជាងផែនការដោយសារខ្វះគ្រូអប់រំពិសេស។

អង្គការសាលារៀនទន្សាយ បានផ្តល់សម្ភារៈបង្រៀនដល់ថ្នាក់រៀនបរិយាប័ន្នចំនួន ២៩ថ្នាក់ ដូចជាប្រអប់ពណ៌ចំនួន ៣៨២ ប្រអប់ ក្រដាសកាតុង ៨៣សន្លឹក ក្រដាសផ្ទាំងធំ ៥២សន្លឹក ការបិទ ១៦ប្រអប់ បង់ស្អិត ២៩ ប្រអប់ ក្រដាសពណ៌ ១៩៤ ប្រអប់ ក្រដាសផ្លាស្ទិកចំនួន ២៩ប្រអប់ ខ្មៅដៃ ១៩៤ប្រអប់ ប្រអប់លេខ ៥០ប្រអប់ ក្រដាសប្លាស្ទិកប្រវែង ១៩៤ម៉ែត្រ ទឹកថ្នាំក្រហម ៦០ប្រអប់ ក្រដាសផ្លាស្ទិក ៣០ប្រអប់ ម៉ាស៊ីនអ៊ុត ៥ សាប៊ូលាងដៃ ១៩៣ដុំ បង់ស្អិតថ្លា ១៩៣ដុំ បង់ស្អិតក្រដាស ១៩៤ដុំ ប៊ិចហ្វឺត ៩៧ដើម ទឹកខ្មៅ ៦០ប្រអប់ និងទឹកក្រហម ៦០ប្រអប់។

ការផ្តល់សម្ភារសិក្សាដល់កុមារក្រៅសាលាដើម្បីមកសាលារៀន

កុមារមានពិការភាពសតិបញ្ញាចំនួន ២៧៨នាក់ (ស្រី៖ ៨៣) ដំណាក់កាលទី១ ក្នុងនោះ ៦២នាក់ (ស្រី៖១៨) បានឡើងថ្នាក់ ២១៦នាក់(ស្រី៖ ៦៥) បន្តរៀនថ្នាក់ដដែល ២០នាក់ (ស្រី៖ ៦) បានបោះបង់ការសិក្សា និង២នាក់ (ស្រី៖ ១) បានបិទករណី។ សិស្សពិការដំណាក់កាលទី១ ទទួលបានអាហារូបករណ៍ពី TCDA មានចំនួនសរុប ៩៤នាក់ (ស្រី៖ ៤៣)។

នៅឆ្នាំ ២០២២ កុមារក្រៅសាលាចំនួន ១០២៨នាក់ (ស្រី៖ ៥០៧) បានចុះឈ្មោះ និងទទួលបានការគាំទ្រពីគម្រោងក្នុងដំណាក់កាលទី២។

- **ផ្តល់អាហារូបករណ៍ដល់កុមារក្រៅសាលា**
  - គម្រោងបានផ្តល់អាហារូបករណ៍សិក្សាដល់កុមារមានពិការភាពចំនួន ៣៧នាក់ (ស្រី៖ ៨)។
  - គម្រោងបានផ្តល់អាហារូបករណ៍សិក្សាដល់កុមារមិនមានពិការភាពចំនួន ៧០៥នាក់ (ស្រី៖ ៣៦៥)។

- **ផ្តល់សម្ភារសិក្សាដល់កុមារក្រៅសាលា**
  - គម្រោងបានផ្តល់សម្ភារសិក្សាដល់សិស្សពីគ្រួសារក្រីក្រចំនួន ១៩៧នាក់ (ស្រី៖ ១០១) សម្ភារទាំងនោះមានដូចជា កង់ កាបូបស្ពាយ និងសៀវភៅសរសេរ)។

ការបញ្ជូនកុមារទៅទទួលសេវាស្តារ និង ព្យាបាល

កុមារមានពិការភាពចំនួន ៦នាក់ (ស្រី៖ ២) ក្នុងនោះ ៥នាក់មកពីស្រុកសំរោងទង ១នាក់ពីស្រុកពួក ត្រូវបានរកឃើញ និងបញ្ជូនទៅទទួលសេវាថែទាំភ្នែក និងត្រចៀក។

លទ្ធផលទី ២៖ កុមារក្រៅសាលាបានទទួលការអប់រំកម្រិតបឋមប្រកបដោយគុណភាពនិងភាពប្រសើរឡើង។

ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយសៀវភៅអប់រំបរិយាប័ន្នមូលដ្ឋាន

សិក្ខាសាលាមួយ ត្រូវបានរៀបចំឡើងនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ មានអ្នកចូលរួមចំនួន ២៨នាក់ (ស្រី៖ ១៦) ក្នុងនោះ ១២នាក់មកពីមន្ទីរ/ការិយាល័យអប់រំ/នាយកសាលា ៤នាក់ជាបុគ្គលិកអង្គការសាលារៀនទន្សាយ បានចូលរួមក្នុងសិក្ខាសាលាអប់រំបរិយាប័ន្ន។ ខ្លឹមសារសិក្ខាសាលាបានគ្របដណ្តប់លើការកំណត់អត្តសញ្ញាណកុមារមានអូទីស្សឹម សតិបញ្ញា ដោនស៊ីនដ្រូម ពិការចលករខួរក្បាល ពិការភាពមើលឃើញ និងការចុះខ្សោយនៃការស្តាប់ ការណែនាំអំពីលក្ខណៈសម្រាប់ថ្នាក់រៀនបរិយាប័ន្ន និងគោលនយោបាយ និងគោលការណ៍ណែនាំការអប់រំបរិយាប័ន្នសម្រាប់កុមារពិការ។

សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការអប់រំបរិយាប័ន្ន ចំនួន ២ដង បានធ្វើឡើងនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ នៅស្រុកច្បារមន ខេត្តកំពង់ស្ពឺ និងថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ នៅស្រុកពួក ខេត្តសៀមរាប។ សិក្ខាសាលាបណ្តុះបណ្តាលបានគ្របដណ្តប់លើការកំណត់អត្តសញ្ញាណកុមារអូទីស្សឹម ពិការភាពសតិបញ្ញា ដោនស៊ីនដ្រូម ពិការចលករខួរក្បាល ពិការភាពក្នុងការស្តាប់ និងពិការភាពក្នុងការមើល ការណែនាំអំពីលក្ខណៈនៃថ្នាក់រៀនបរិយាប័ន្ន និងការចែករំលែកគោលនយោបាយ និងគោលការណ៍ណែនាំដើម្បីគាំទ្រការអប់រំបរិយាប័ន្នសម្រាប់កុមារពិការ។ អ្នកចូលរួមចំនួន ៤៧នាក់ (ស្ត្រី៖ ១១) រួមមាន ៤នាក់ (ស្ត្រី៖ ២) មកពីមន្ទីរអប់រំ ៣នាក់ (ស្ត្រី៖ ០)មកពីការិយាល័យអប់រំ ១៦នាក់ (ស្ត្រី៖ ៥) ជានាយកសាលា និង ៨នាក់ (ស្ត្រី៖ ៤) ជាបុគ្គលិកសាលារៀនទន្សាយ ដែលបានចូលរួមក្នុងសិក្ខាសាលាទាំងពីរនេះ។

ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអប់រំពិសេសសម្រាប់គ្រូបង្រៀនកុមារមានពិការសតិបញ្ញា នាយកសាលា និងក្រុមការងារគ្រប់គ្រងបច្ចេកទេសកម្រិតស្រុក

សិក្ខាសាលាចំនួន២ បានធ្វើឡើងនៅថ្ងៃទី៥-៦ ខែឧសភា ឆ្នាំ២០២២ នៅស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានអ្នកចូលរួមចំនួន ៤៤៦នាក់ (ស្ត្រី៖ ៣៧) រួមមានទាំងគ្រូបង្រៀនពិសេសចំនួន ៤០នាក់ និង៦នាក់ជាបុគ្គលិក បានចូលរួមសិក្ខាសាលា

នេះ។ នៅថ្ងៃទី ១១-១២ ខែឧសភា ឆ្នាំ២០២២ នៅស្រុកពួក និងខេត្តសៀមរាប ដែលមានអ្នកចូលរួមចំនួន ២៣នាក់ (ស្ត្រី៖ ១៧) រួមមានទាំងគ្រូបង្រៀនពិសេសចំនួន ១៥នាក់ និងបុគ្គលិកទន្សាយ ចំនួន ៧នាក់។ ខ្លឹមសិក្ខាសាលាបណ្តុះបណ្តាលបានគ្របដណ្តប់លើការកំណត់អត្តសញ្ញាណកុមារអូទីស្សឹម ពិការភាពសតិបញ្ញា ដោនស៊ីនដ្រូម ពិការចលករខ្លួរក្បាល ពិការភាពក្នុងការស្តាប់ និងពិការភាពក្នុងការមើល ការណែនាំអំពីលក្ខណៈនៃថ្នាក់រៀនបរិយាប័ន្ន និងការចែករំលែកគោលនយោបាយ និងគោលការណ៍ណែនាំដើម្បីគាំទ្រការអប់រំបរិយាប័ន្នសម្រាប់កុមារពិការ។

សិក្ខាសាលាអប់រំពិសេសចំនួន២ ធ្វើឡើងនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ នៅស្រុកច្បារមន ខេត្តកំពង់ស្ពឺ និងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ នៅស្រុកពួក ខេត្តសៀមរាប ដែលមានអ្នកចូលរួមចំនួន ៤៦នាក់ (ស្ត្រី៖ ៣៣) រួមមានទាំង ១នាក់មកពីមន្ទីរអប់រំ ១៩នាក់ (ស្ត្រី៖ ១៣)ជាគ្រូបង្រៀនបរិយាប័ន្ន និង ៧នាក់ (ស្ត្រី៖ ៣) ជាបុគ្គលិកអង្គការសាលារៀនទន្សាយបានចូលរួមសិក្ខាសាលាទាំងពីរនេះ។ ខ្លឹមសិក្ខាសាលាបណ្តុះបណ្តាលបានគ្របដណ្តប់លើការកំណត់អត្តសញ្ញាណកុមារអូទីស្សឹម ពិការភាពសតិបញ្ញា ដោនស៊ីនដ្រូម ពិការចលករខ្លួរក្បាល ពិការភាពក្នុងការស្តាប់ និងពិការភាពក្នុងការមើល ការណែនាំអំពីលក្ខណៈនៃថ្នាក់រៀនបរិយាប័ន្ន និងការចែករំលែកគោលនយោបាយ និងគោលការណ៍ណែនាំដើម្បីគាំទ្រការអប់រំបរិយាប័ន្នសម្រាប់កុមារពិការ និងរបៀបឧបករណ៍ឌីជីថលជួយកុមារពិការ និងការបញ្ជូនបន្ត។

ការរៀបចំកិច្ចប្រជុំគាំទ្របច្ចេកទេសគ្រូដើម្បីផ្តល់ការគាំទ្រដល់ថ្នាក់សមាហរណកម្មនិងអប់រំបរិយាប័ន្ននៅសាលាគោលដៅ

កិច្ចប្រជុំគាំទ្របច្ចេកទេសចំនួន ៣០ដង ត្រូវបានធ្វើឡើង (៨ដងនៅភ្នំពេញ ៦ដងនៅអង្គស្នួល ៤ដងនៅសំរោងទង ៤ដងនៅកណ្តាលស្ទឹង ៤ដងនៅច្បារមន និង ៤ដងនៅពួក) ដែលមានអ្នកចូលរួមសរុបចំនួន ៦៩នាក់ (ស្ត្រី៖ ៥៤) ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសបង្រៀនសិស្សពិការក្នុងថ្នាក់អប់រំបរិយាប័ណ្ណ និងថ្នាក់សមាហរណកម្មនៅតាមសាលាគោលដៅ។

ការរៀបចំទស្សនៈកិច្ចត្រួតពិនិត្យ និងតាមដានសកម្មភាពការងារនៅក្នុងតំបន់គោលដៅ

ការចុះពិនិត្យតាមដាន និងវាយតម្លៃចំនួន ៧ដង ត្រូវបានធ្វើឡើងដោយនាយកប្រតិបត្តិ ប្រធានគម្រោង និងមន្ត្រីត្រួតពិនិត្យតាមដាន នៅតំបន់គោលដៅ រួមមាន ភ្នំពេញ អង្គស្នួល កណ្តាលស្ទឹង សំរោងទង ច្បារមន និងពួក ដើម្បីជួបសំណេះសំណាលការងារជាមួយប្រធានកម្មវិធីតាមស្រុក លោកគ្រូ អ្នកគ្រូ នាយកសាលា មន្ត្រីការិយាល័យអប់រំ អភិបាលស្រុក និងឪពុកម្តាយអាណាព្យាបាលសិស្ស។

លទ្ធផលទី ៣៖ សមត្ថកិច្ច និងសិទ្ធិកុមារក្រៅសាលា បានពង្រឹងការទទួលខុសត្រូវគ្នាទៅវិញទៅមក។

រៀបចំពិធីបើកបវេសនកាលដើម្បីចុះឈ្មោះកុមារក្រៅសាលានៅតាមសាលាគោលដៅ

ការបើកបវេសនកាលសិក្សាចំនួន៤ដង ត្រូវបានរៀបចំឡើង ១ដងនៅអង្គស្នួល ១ដងនៅច្បារមន ១ដងនៅសំរោងទង និង១ដងនៅស្រុកពួក។ អ្នកចូលរួមមានសរុបចំនួន ៣០៦៥នាក់ (ស្ត្រី៖ ១៤៦០)។

ការរៀបចំទិវាអូទីសឹមអន្តរជាតិ

ព្រឹត្តិការណ៍ទិវាអូទីស្សឹមចំនួន២បានធ្វើនៅរាជធានីភ្នំពេញ និងស្រុកអង្គស្នួល នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២២ នៅតាមសាលាគោលដៅចំនួន ១៦ សាលា។ អ្នកចូលរួមចំនួន ៩៥៥នាក់ (ស្ត្រី៖ ៥៥៦) មានកុមារចំនួន ៨១១នាក់ (ស្រី៖ 446 និងកុមារមានពិការភាព ១៩៥នាក់) ១១២ (ស្ត្រី៖ ៩០) ជាគ្រូបង្រៀន គ្រូបង្រៀនពិសេស នាយកសាលា និងមន្ត្រីអប់រំស្រុក និង ២៧នាក់ (ស្ត្រី៖ ១៦) ជាមាតាបិតា និង១នាក់ជាមេភូមិ និង ៤នាក់ជាមន្ត្រី ស.ស.យ.ក បានចូលរួមក្នុងព្រឹត្តិការណ៍ទាំងនេះ។

ព្រឹត្តិការណ៍ដែលរៀបចំឡើងតាមរយៈការប្រមូលផ្តុំកាតីពាក់ព័ន្ធនានាមកលេងជាមួយកុមារមានពិការភាពក្នុងសាលា ក្នុងគោលបំណងដើម្បីលើកកម្ពស់សិទ្ធិសម្រាប់ការចូលរួម និងការទទួលបានការអប់រំស្មើៗគ្នាដល់កុមារដែលមានអូទីស្សឹម។

ការរៀបចំការប្រជុំជាមួយឪពុកម្តាយនៅក្នុងតំបន់គោលដៅ

កិច្ចប្រជុំមាតាបិតាចំនួន ២៥ដង ត្រូវបានធ្វើឡើងនៅស្រុកអង្គស្នួល កណ្តាលស្ទឹង សំរោងទង ស្រុកច្បារមន និងស្រុកពួក។ អ្នកចូលរួមមានចំនួនសរុប ១៧៣នាក់ (ស្ត្រី៖ ១០៩)។

ការធ្វើយុទ្ធនាការតាមសាលារៀនដើម្បីចុះឈ្មោះកុមារក្រៅសាលាក្នុងតំបន់គោលដៅ

យុទ្ធនាការសិក្សាមួយ ត្រូវបានធ្វើឡើងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ នៅស្រុកកណ្តាលស្ទឹង ក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការ AAR ជប៉ុន។ អ្នកចូលរួមមានសរុបចំនួន ១១៦នាក់ (ស្ត្រី៖ ៤៤) ក្នុងព្រឹត្តិការណ៍នេះ។ គោលបំណងនៃយុទ្ធនាការនេះគឺដើម្បីលើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍អំពីការបើកវគ្គសិក្សាឆ្នាំថ្មី និងលើកកម្ពស់ការចុះឈ្មោះចូលរៀនថ្មី។

ធ្វើយុទ្ធនាការកំណត់ផែនទីសាលាដើម្បីកំណត់អត្តសញ្ញាណកុមារក្រៅសាលា

យុទ្ធនាការផែនទីខ្នងផ្ទះចំនួន ៣១ដង ធ្វើឡើង ៦ដងនៅស្រុកអង្គស្នួលចំនួន ៨ដងនៅកណ្តាលស្ទឹងចំនួន ៩ដង នៅសំរោងទង ២ដងនៅច្បារមន និង ៦ដងនៅពួក។ នាយកសាលាចំនួន ៣១ នាក់ចូលរួមសកម្មភាពកំណត់ផែនទីខ្នងផ្ទះនេះ។ គោលបំណងនៃការកំណត់ផែនទីខ្នងផ្ទះ គឺដើម្បីកំណត់អត្តសញ្ញាណកុមារក្រៅសាលា សម្រាប់ការចុះឈ្មោះចូលរៀន។

ទិវាសិទ្ធិជនមានពិការភាពនៅក្នុងសហគមន៍និងថ្នាក់ជាតិ

ទិវាសិទ្ធិជនមានពិការភាពនៅថ្នាក់ជាតិ

អ្នកចូលរួមចំនួន ៤០នាក់ (ស្ត្រី៖ ៣៨) ក្នុងនោះសិស្សនិងយុវជនមានពិការភាព ៣០នាក់ និងមន្ត្រីអង្គការសាលារៀនទន្សាយ ១០នាក់ បានចូលរួមក្នុងទិវាជនពិការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការនៅរាជធានីភ្នំពេញនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២២ ។

ទិវាសិទ្ធិជនពិការភាពនៅខេត្តសៀមរាប

អ្នកចូលរួមចំនួន ៧១នាក់ (ស្ត្រី៖ ២៥) រួមមានសិស្សចំនួន ២០នាក់ ជនមានពិការភាព ១២នាក់ មាតាបិតា ១៥នាក់ គ្រូពិសេស ៨នាក់ នគរបាល ៦នាក់ នាយកសាលា ៣នាក់ អាជ្ញាធរមូលដ្ឋាន ៦នាក់ និងបុគ្គលិកអង្គការសាលារៀនទន្សាយ ១ នាក់ បានចូលរួមក្នុងព្រឹត្តិការណ៍នេះ នៅខេត្តសៀមរាប ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២។

ការរត់ដើម្បីការផ្លាស់ប្តូរ

កម្មវិធីរត់មួយបានរៀបចំឡើងនៅខេត្តសៀមរាប នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ មានអ្នកចូលរួមចំនួន ៧១នាក់ (ស្ត្រី៖ ២៥) រួមមានសិស្សចំនួន ២០នាក់ ជនមានពិការភាពចំនួន ១២នាក់ មាតាបិតាសិស្ស ១៥នាក់ គ្រូបង្រៀនអប់រំពិសេសចំនួន ៨នាក់ ប៉ូលីសចំនួន ៦នាក់ នាយកសាលាចំនួន ៣នាក់ អាជ្ញាធរមូលដ្ឋានចំនួន ៦នាក់ និងបុគ្គលិកអង្គការសាលាទន្សាយចំនួន ១នាក់។ គោលបំណងនៃព្រឹត្តិការណ៍នេះគឺដើម្បីផ្ញើសារទៅកាន់ជនមានពិការភាព ក្នុងសហគមន៍ ដើម្បីចុះឈ្មោះកំណត់អត្តសញ្ញាណជនមានពិការភាព តាមរយៈយុទ្ធនាការ និងចែកខិតប័ណ្ណ និងស្វែងរកការគាំទ្រ និងសហការពីអាជ្ញាធរមូលដ្ឋានស្រុក លើការស្នើសុំចុះឈ្មោះកំណត់អត្តសញ្ញាណជនពិការមានពិការភាព។

ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីអំពីច្បាប់ គោលនយោបាយ និងបទបញ្ជាពាក់ព័ន្ធកុមារក្រៅសាលា និងកុមារពិការ សតិបញ្ញា រួមទាំងការបណ្តុះបណ្តាលតស៊ូមតិ និងការរំលេចបំពានផ្លូវភេទក្នុងតំបន់គោលដៅ។

នៅខេត្តសៀមរាបនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ អង្គការសាលារៀនទន្សាយបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីអំពីច្បាប់ គោលនយោបាយ និងបទបញ្ជាពាក់ព័ន្ធកុមារក្រៅសាលា។ អ្នកចូលរួមចំនួន ៣៨នាក់ (ស្ត្រី៖ ១៨) រួមទាំងមាតាបិតា គ្រូបង្រៀនអប់រំពិសេស នាយកសាលា មន្ទីរ/ការិយាល័យអប់រំ មន្ទីរ/ការិយាល័យសង្គមកិច្ច ដៃគូអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានបានចូលរួមសិក្ខាសាលាស្តីពីការអប់រំរួមបញ្ចូលគោលនយោបាយផ្សព្វផ្សាយនេះ។ អ្នកចូលរួមបានដឹងពី

ដំណើរការនៃការដាក់ពាក្យសុំការងារ និងការកំណត់អត្តសញ្ញាណសម្រាប់យុវជនដែលមានពិការភាពបញ្ញា។ អ្នកចូលរួមបានដឹងពីសេវាសុខុមាលភាពសង្គមដែលរដ្ឋាភិបាលបាននិងកំពុងផ្តល់ជូនដល់យុវជនដែលមានពិការភាពផ្នែកសតិបញ្ញា ជាពិសេសដំណើរការស្នើសុំប័ណ្ណពិការ។ មន្ត្រីតំណាងមន្ទីរសង្គមកិច្ច បានលើកទឹកចិត្តដល់ឪពុកម្តាយ លោកគ្រូ អ្នកគ្រូ យុវជនមានពិការភាព នាយកសាលា និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីជួយជនមានពិការភាពឱ្យទទួលបានប័ណ្ណពិការ។

ការរៀបចំសិក្ខាសាលាបណ្តុះបណ្តាលឪពុកម្តាយនិងអាជ្ញាធរមូលដ្ឋានក្នុងតំបន់គោលដៅ អំពីការប្រើប្រាស់បណ្តាញសង្គម ដូចជាហ្វេសប៊ុក តេលេក្រាម ដើម្បីចែករំលែកនិងផ្តល់យោបល់

អង្គការសាលារៀនទន្សាយ បានបើកវគ្គបណ្តុះបណ្តាលប្រព័ន្ធផ្សព្វផ្សាយសង្គមចំនួន២ដងនៅរាជធានីភ្នំពេញនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២ និងនៅខេត្តសៀមរាបនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២។ សិក្ខាកាមចំនួន ៣៦នាក់ (ស្ត្រី៖ ២៣) រួមទាំងស្ត្រី/យុវជនពិការ ឪពុកម្តាយ គ្រូបង្រៀន នាយកសាលា និងមន្ត្រីសង្គមកិច្ច បានចូលរួម។ នៅក្នុងការបណ្តុះបណ្តាលប្រព័ន្ធផ្សព្វផ្សាយសង្គមនេះ។ អ្នកចូលរួមទាំងអស់បានរៀនពីរបៀបប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា ហ្វេសប៊ុក តេលេក្រាម (ចែករំលែកព័ត៌មាន យោបល់ និងសរសេរសារ) ដើម្បីបញ្ចេញសំឡេងអំពីតម្រូវការរបស់ពួកគេ ដូចជាការអប់រំ និងសិទ្ធិជនពិការ ដឹងថាស្ថាប័នណា កន្លែងណាដែលពួកគេអាចតាមដាន ឬបន្ថែម។ សម្រាប់ព័ត៌មានដែលមានប្រយោជន៍ និងអ្វីដែលពួកគេគួរ និងមិនគួរ និងរបៀបដើម្បីទទួលបានការបញ្ចូលប្រកបដោយសីលធម៌ និងការគោរព ពួកគេរៀនពីរបៀបចែករំលែកព័ត៌មាន និងមតិយោបល់ប្រកបដោយសីលធម៌ និងការគោរព។

ការរៀបចំវេទិកាថ្នាក់ក្រោមជាតិចំនួន ជាមួយស្ត្រីម្តាយ/ ក្មេងស្រីពិការសតិបញ្ញា អ្នកអប់រំ និង អាជ្ញាធរមូលដ្ឋាន (ក្រសួងអប់រំ ក្រសួងសង្គមកិច្ច មន្ទីរអប់រំ ការិយាល័យអប់រំ ក្រុមប្រឹក្សាសម្មភាពជនពិការ និងស្ថាប័នពាក់ព័ន្ធ)

វេទិកាការងារថ្នាក់ក្រោមជាតិមួយ ត្រូវបានរៀបចំឡើងនៅខេត្តសៀមរាប ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២។ អ្នកចូលរួមចំនួន ៥៨នាក់ (ស្ត្រី៖ ៣១) រួមមាន យុវជនមានពិការភាព ឪពុកម្តាយ គ្រូអប់រំពិសេស នាយកសាលា ដៃគូអង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន មន្ទីរ/ការិយាល័យអប់រំ និងបុគ្គលិកអង្គការសាលារៀនទន្សាយ បានចូលរួមក្នុងវេទិកានេះ។ អ្នកចូលរួមបានដឹងពីដំណើរការនៃការដាក់ពាក្យសុំការងារ និងការកំណត់អត្តសញ្ញាណសម្រាប់យុវជនដែលមានពិការភាពសតិបញ្ញា សេវាសង្គមដែលរដ្ឋាភិបាលបាននិងកំពុងផ្តល់ជូនដល់យុវជនដែលមានពិការភាពផ្នែកសតិបញ្ញា ជាពិសេសដំណើរការដាក់ពាក្យសុំលិខិតបញ្ជាក់ពិការភាព។

ការរៀបចំវេទិកាថ្នាក់ជាតិជាមួយស្ត្រីម្តាយ/ ក្មេងស្រីមានពិការភាពសតិបញ្ញា អ្នកដឹកនាំធុរកិច្ច និងអ្នកជំនួញមកពីវិស័យឯកជនដើម្បីធ្វើការតស៊ូមតិដាក់បញ្ចូលយុវជនមានពិការភាពសតិបញ្ញាក្នុងទីផ្សារការងារកម្ពុជា

អង្គការសាលារៀនទន្សាយ បានសហការជាមួយក្រសួងសង្គមកិច្ច អង្គការ EPC, PAFiD, NEA, Human Inclusion, និងអង្គការគ្រួសារថ្មី ដើម្បីរៀបចំវេទិកាជាតិស្តីពីការងារបរិយាប័ន្នសម្រាប់ជនពិការ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ នៅសណ្ឋាគារភ្នំពេញ។

យោងតាមរបាយការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានអ្នកចូលរួមចំនួន ១៦៨នាក់ ស្ត្រី៖) (៧៧រួមមាន មន្ត្រីក្រសួងការិយាល័យសង្គមកិច្ច យុវជនមានពិការភាព/មន្ទីរ/ អាណាព្យាបាល គ្រូបង្រៀនអប់រំពិសេស អង្គការ NEA, CAMFEBA, GMAC និងផ្នែកឯកជន។ អ្នកចូលរួមមកពីអង្គការសាលារៀនទន្សាយ មានចំនួន ២០នាក់ ស្ត្រី៖) (១១បានអញ្ជើញឱ្យចូលរួមក្នុងវេទិកាការងារបរិយាប័ន្ន។ អ្នកចូលរួមបានដឹងពីដំណើរការនៃការដាក់ពាក្យសុំការងារ និងការកំណត់អត្តសញ្ញាណសម្រាប់យុវជនដែលមានពិការភាពសតិបញ្ញា សេវាសង្គមដែលរដ្ឋាភិបាលបាននិងកំពុងផ្តល់ជូនដល់យុវជនដែលមានពិការភាពសតិបញ្ញា ជាពិសេសឱកាសទទួលបានការងារធ្វើ។

ក្រសួងសង្គមកិច្ចលើកទឹកចិត្តដល់មាតាបិតាយុវជនមានពិការភាពសតិបញ្ញា វិស័យឯកជន ក្រសួងការងារ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីជួយជនពិការឱ្យទទួលបានជំនាញ និងទេពកោសល្យសក្តានុពលរបស់ពួកគេ។

ការសហការជាមួយក្រសួងអប់រំ និងភាគីពាក់ព័ន្ធ)NEP, CRS, HHC,Kroursar Thmey, AAR Japan, AEA, មូលនិធិកុមារ, RTI, Save the Children, តំណាងឱពុកម្តាយដើម្បីរៀបចំវេទិកាអប់រំអប់រំបរិយាប័ន្នថ្នាក់ជាតិ (

អង្គការសាលារៀនទន្សាយ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីរៀបចំវេទិកាជាតិលើកទី១០ ស្តីអំពីការអប់រំបរិយាប័ន្ន ក្រោមប្រធានបទ" រួមគ្នាផ្តល់អាទិភាពលើការអប់រំបរិយាប័ន្នសម្រាប់កុមារពិការបន្ទាប់ពីកូវីដនៅគ្រប់កម្រិត"។ វេទិកានេះបានប្រារព្ធឡើងនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ។ អ្នកចូលរួមចំនួន ១៣២នាក់ (ស្ត្រី៖ ៥៣)មកពីក្រសួងអប់រំ យុវជន និងកីឡា តំណាងអង្គការយូនីសេហ្វប្រចាំកម្ពុជា មន្ទីរការិយាល័យ/អប់រំស្រុក នាយកសាលា គ្រូបង្រៀន មាតាបិតា កុមារពិការ តំណាងដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ព័ន្ធ។ វេទិកានេះរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីសមាជិក WGED។ គោលបំណងនៃវេទិកាជាតិ គឺដើម្បី៖

- ចែករំលែកបទពិសោធន៍អំពីផលប៉ះពាល់ចំពោះសិស្សពិការអំឡុងពេល និងក្រោយកូវីដ
- ចែករំលែកដំណោះស្រាយអាទិភាព ដើម្បីបំពេញតម្រូវការរបស់សិស្សមានពិការភាពសតិបញ្ញា
- បង្កើនការវិនិយោគ និងកៀរគរធនធានដើម្បីដោះស្រាយការបោះបង់ការសិក្សារបស់សិស្សពិការក្នុងបរិបទនៃការអប់រំបរិយាប័ន្ននៅថ្នាក់ក្រោមជាតិ។

ការគៀរគរការគាំទ្រ និងត្រួតពិនិត្យជាមួយក្រសួងអប់រំយុវជននិងកីឡាទាក់ទងនឹងការបង្កើនការគាំទ្រសម្រាប់សកម្មភាពនិងគម្រោងរបស់អង្គការសាលារៀនទន្សាយ

អង្គការសាលារៀនទន្សាយ បានអញ្ជើញនាយកដ្ឋានអប់រំពិសេស នៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចុះត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោង នៅស្រុកអង្គស្នួល ខេត្តកណ្តាល។ គោលបំណងនៃទស្សនកិច្ចនេះគឺដើម្បីស្វែងរកការគាំទ្រគម្រោងកុមារក្រៅសាលាពីក្រសួងអប់រំ យុវជន និងកីឡា។ ប្រតិភូចំនួន ២៤នាក់ (ស្ត្រី៖ ១១) បានចូលរួម រួមមាន ក្រសួង/មន្ទីរ/ការិយាល័យអប់រំ នាយកសាលា គ្រូបង្រៀន អង្គការដៃគូ និងបុគ្គលិកសាលារៀនទន្សាយ ចូលរួមក្នុងការត្រួតពិនិត្យ និងវាយតម្លៃនេះ។ ក្រសួងអប់រំ យុវជន និងកីឡា បានយល់ដឹងអំពីដំណើរការនៃការអនុវត្តការអប់រំសម្រាប់កុមារ ជាពិសេសក្នុងថ្នាក់បរិយាប័ន្ន។ ក្រសួងអប់រំ បានលើកទឹកចិត្តគ្រូបង្រៀន និងនាយកសាលា ឱ្យជួយដល់កុមារដែលមានតម្រូវការពិសេស ហើយក្រសួងអប់រំរកឃើញលទ្ធភាពក្នុងការដាក់បញ្ចូលគម្រោងនេះជាមួយនឹងការគាំទ្រពីរដ្ឋាភិបាល។

ចែករំលែកឯកសារ ឬកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវលើបញ្ហាកុមារក្រៅសាលា

អង្គការសាលារៀនទន្សាយសហការជាមួយសារព័ត៌មានថ្មីដើម្បីផ្សព្វផ្សាយអត្ថបទជំរុញឱពុកម្តាយបញ្ជូនកូនទៅសាលារៀន "promote parent to send their children to school"

៣. ឧបសគ្គ

- ឥទ្ធិពលកូវីដ-១៩ នៅតែមាន ហើយរដ្ឋាភិបាលនៅតែបន្តការពិនិត្យ។
- សាលារៀននៅតែបិទទ្វារ។ យើងអាចគាំទ្រកុមារបានតែតាមអ៊ីនធឺណិត និងផ្ទាល់ម្តងម្កាល។ ថវិកាសាលាត្រូវបានកាត់បន្ថយ ដោយសារជំងឺរាតត្បាត។
- រដ្ឋាភិបាលចាត់វិធានការតឹងរ៉ឹងយ៉ាងម៉ឺងម៉ាត់ មិនអនុញ្ញាតឲ្យប្រជាពលរដ្ឋរៀបចំការប្រជុំណាមួយនៅក្នុងសាលាឡើយ។

- លោកគ្រូ អ្នកគ្រូ និងមាតាបិតាសិស្សពិការ មានការអាក់អន់ស្រពន់ចិត្តក្នុងការសិក្សា និងការប្រាស្រ័យទាក់ទងគ្នាដោយប្រើបច្ចេកវិទ្យា។ វាផ្លាស់ប្តូរលឿនពេក។
- ខ្វះវគ្គសិក្សាភាសាក្នុងប្រព័ន្ធអ៊ីនធឺណិត ដូច្នេះត្រូវការពេលវេលាដើម្បីផលិតវាសម្រាប់ជួយសិស្ស។
- គ្រួសារមានការប្រឈមនឹងជំងឺរាតត្បាតខ្លាំង ដូច្នេះពួកគេមិនសូវយកចិត្តទុកដាក់លើការអប់រំកូនរបស់កូនៗទេ។ ដូច្នេះកុមារលេងនៅក្នុងសហគមន៍ ហើយប្រឈមមុខនឹងហានិភ័យ ដូចជាការរើសអើង ការរំលោភបំពានផ្លូវកាយ និងផ្លូវភេទ។
- ជំនួយថវិកាមានការខ្វះខាតពីម្ចាស់ជំនួយ។
- ការយល់ដឹងអំពីប្រភេទនៃកុមារក្រៅសាលានៅមានកម្រិត និងខ្វះផែនការអភិវឌ្ឍន៍សាលាទាំងមូល។
- ធនធានសាលាមានកម្រិត ដូចជាគ្រូបង្រៀនជំនាញបន្ថែម អាហារូបករណ៍ សម្ភារៈសិក្សា និងលទ្ធភាពប្រើប្រាស់ដើម្បីទាក់ទាញកុមារក្រៅសាលាឱ្យមកសាលារៀន។

៤. យុទ្ធសាស្ត្រ និងផែនការបន្តាប់

- យើងនឹងប្រើវិធីសាស្ត្របង្រៀនអនឡាញ ក្នុងអំឡុងពេលកូវីដ អង្គការសាលារៀនទន្យាយនឹងបង្កើតខ្លឹមសារមេរៀនតាមអនឡាញបន្ថែមទៀត ទាំងផលិតវីដេអូ និងសម្ភារចែករំលែកដល់ឪពុកម្តាយតាមអ៊ីនធឺណិត គាំទ្រកុមារតាមរយៈឪពុកម្តាយរបស់ពួកគេនៅលើអ៊ីនធឺណិតប្រឈមមុខនឹងការប្រជុំ។
- ជំរុញការគាំទ្រតាមផ្ទះ តាមរយៈសកម្មភាពបង្រៀនតាមផ្ទះ។
- ការកសាងសមត្ថភាពលើវិធីជួយកុមារទាំងតាមប្រព័ន្ធអនឡាញ និងបង្រៀនផ្ទាល់។
- ផលិតសម្ភារបង្រៀនតាមអ៊ីនធឺណិត និងបង្រៀនផ្ទាល់ ដើម្បីជួយកុមារនៅផ្ទះ។
- រៀបចំពេលវេលាបន្ថែមទៀតសម្រាប់ការប្រជុំ/វេទិការបស់មាតាបិតាតាមអ៊ីនធឺណិត និងបង្កើតសមាគមមាតាបិតានៅក្នុងសហគមន៍ និងការកសាងសមត្ថភាពលើសិទ្ធិកុមារមានពិការភាព ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង ការបញ្ចុះបញ្ចូលការតស៊ូមតិ ដល់អាជ្ញាធរក្នុងការរួមបញ្ចូលកុមារពិការទៅក្នុងផែនការអភិវឌ្ឍន៍សហគមន៍។
- តាមដាន និងពង្រឹងសកម្មភាពលើកកម្ពស់ការយល់ដឹងដល់មាតាបិតា និងអាជ្ញាធរមូលដ្ឋាន អំពីតម្រូវការកុមារពិការក្នុងអំឡុងពេលជំងឺកូវីដ។
- សហការជាមួយវិទ្យាស្ថានជាតិសម្រាប់ការអប់រំពិសេស ដើម្បីបណ្តុះបណ្តាលគ្រូ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការបង្រៀនកុមារក្នុងថ្នាក់សមាហរណកម្ម និងថ្នាក់បរិយាប័ន្នក្នុងសាលាបឋមសិក្សារបស់រដ្ឋាភិបាល។
- អង្គការសាលារៀននឹងរៀបចំវគ្គបណ្តុះបណ្តាលមិនត្រឹមតែគ្រូអប់រំពិសេសប៉ុណ្ណោះទេ តែនឹងរៀបចំការបណ្តុះបណ្តាលដល់គ្រូផ្សេងៗទៀតនៅក្នុងសាលាទាំងមូលផងដែរ។
- យើងនឹងពង្រឹងសកម្មភាពលើកកម្ពស់ការយល់ដឹងដល់មាតាបិតា នាយកសាលា និងអាជ្ញាធរមូលដ្ឋានអំពីការកំណត់អត្តសញ្ញាណពិការភាព តម្រូវការរបស់កុមារក្រៅសាលា និងសិទ្ធិរបស់កុមារក្នុងការទទួលបានការអប់រំស្មើៗគ្នា។
- ការបញ្ចុះបញ្ចូល និងការតស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋាន នាយកសាលា មន្ទីរ/ការិយាល័យអប់រំ ដើម្បីបង្កើនការយកចិត្តទុកដាក់របស់ពួកគេលើសិទ្ធិកុមារ ជាពិសេសការអភិវឌ្ឍន៍កុមារ។
- ដើម្បីស្វែងរកម្ចាស់ជំនួយដើម្បីធានាការផ្តល់មូលនិធិរយៈពេលយូរ។

៥. ឧបសម្ព័ន្ធ៖ រូបភាពសកម្មភាពផ្សេងៗ

សកម្មភាពពិគ្រោះយោបល់ជាមួយគ្រួសាររលើមុខរបរខ្នាតតូច





សកម្មភាពជួបជាមួយក្រុមហ៊ុន ដើម្បីស្វែងរកការងារសម្រាប់យុវជនមានពិការភាពសតិបញ្ញា









សកម្មភាពសិក្ខាសាលាផ្សព្វផ្សាយច្បាប់សិទ្ធិជនពិការដល់អាជ្ញាធរមូលដ្ឋាន





សកម្មភាពទស្សនៈកិច្ចសិក្សានៅអង្គការ GRET





សកម្មភាពបណ្តុះបណ្តាលអំពីបណ្តាញសង្គម

អំពីការងារយុវជនមានពិការភាពសតិបញ្ញា





សកម្មភាពសម្ពោធអាគារ និងបណ្ណាល័យឌីជីថលនៅសាលាទួលគោក









សកម្មភាពនៅក្នុងបណ្ណាល័យឌីជីថល សាលាទួលគោក





សកម្មភាពទស្សនៈកិច្ចសិក្សារបស់ក្រសួងអប់រំនៅអង្គស្នួល





សកម្មភាពវេទិកាជាតិស្តីអំពីការងារសម្រាប់ជនពិការ





សកម្មភាពរត់នៅខេត្តសៀមរាប





សកម្មភាពប្រជុំមាតាបិតាសិស្ស





សកម្មភាពប្រជុំមបច្ចេកទេសជាមួយគ្រូបង្រៀន



សកម្មភាពបណ្តុះបណ្តាលអំពីមាត់ធ្មេញ



៦. ករណីសិក្សា

កុមារ ឈ្មោះ ខៀវ សុធារិទ្ធ



កុមារ ខៀវ សុធារិទ្ធ អាយុ ១៧ឆ្នាំ មានពិការភាពអូទីស្សឹម។ សុធារិទ្ធ រស់នៅជាមួយឪពុកម្តាយ ក្នុងសង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ គ្រួសាររបស់ សុធារិទ្ធ គឺជាគ្រួសារក្រីក្រមួយដែលមានសមាជិកគ្រួសារប្រាំនាក់ ក្នុងនោះមានបងប្រុសបងស្រីរបស់គាត់។ ឪពុកគាត់ជាសន្តិសុខនៅហាងមួយ ហើយម្តាយគាត់ជាអ្នកបោសសម្អាតនៅសណ្ឋាគារមួយ។ សុធារិទ្ធ ចាប់ផ្តើមរៀននៅសាលាទន្សាយនៅឆ្នាំ២០១៥ ហើយគាត់កំពុងរៀនថ្នាក់ទី៣នៅសាលាបឋមសិក្សាទួលគោកក្នុងរាជធានីភ្នំពេញ។ មុនចូលរៀន គាត់ជាក្មេងរពឹសខ្លាចគេ មិននិយាយច្រើន មិនចេះសរសេរ ឬគណនា ។ល។

ក្នុងអំឡុងពេលនៃការរាតត្បាតកូវីដ ឪពុកម្តាយរបស់គាត់បានបាត់បង់ការងារ និងរស់នៅដោយមិនមានប្រាក់ចំណូលគ្រប់គ្រាន់។ ដូច្នេះហើយ អាជ្ញាធរមូលដ្ឋានបានផ្តល់ម្ហូបអាហារមួយចំនួនដល់ពួកគាត់ដូចជា អង្ករ ទឹកត្រី ទឹកស៊ីអ៊ីវ ត្រីខកំប៉ុង ប្រេងឆា មីជាដើម។ អង្គការសាលារៀនទន្សាយ ក៏បានផ្តល់អាហារូបករណ៍ជាអំណោយដល់គ្រួសាររបស់សុធារិទ្ធ ដូចជាម្ហូបអាហារមួយចំនួន និងសម្ភារៈសិក្សាផងដែរ។ ពេលនេះស្ថានភាពគ្រួសារបានធូរស្រាល ដោយសារឪពុកទទួលបានប្រាក់ខែពីសន្តិសុខ និងប្រាក់ចំណូលបន្ថែមពីអាជីវកម្មម៉ូតូឌុប។ ម្តាយគាត់ធ្វើការជាអ្នកបោសសម្អាតនៅសណ្ឋាគារមួយ ហើយប្អូនស្រីរបស់គាត់ក៏ទទួលបានការងារប្រាក់ខែដែរ។



បន្ទាប់ពីចូលរៀន ឥឡូវសុធារិទ្ធអាចអាននិងសរសេរពាក្យខ្លះបាន។ គាត់អាចគណនាលេខ ២ខ្ទង់ បូកឬដក។ ជាធម្មតា គាត់ធ្វើកិច្ចការផ្ទះ ហើយដាក់ជូនគ្រូទាន់ពេល។ គាត់មានមិត្តភ័ក្តិ និងចូលចិត្តរៀន ក៏ដូចជាលេងជាមួយមិត្តភក្តិរបស់គាត់នៅសាលា។ នៅផ្ទះសុធារិទ្ធជួយគ្រួសារការងារមួយចំនួន ដូចជាបោកខោអាវ សម្អាតផ្ទះ ថែទាំផ្ទះជាដើម។

សម្រាប់ឆ្នាំ២០២៣ខាងមុខ សុធារិទ្ធនឹងក្លាយជាយុវជនវ័យ១៨ឆ្នាំ។ គាត់នឹងត្រូវបានផ្លាស់ប្តូរទៅចូលរួមវគ្គបណ្តុះបណ្តាលជំនាញរស់នៅដូចជា អនាម័យ និងអនាម័យ ជំនាញរស់នៅប្រចាំថ្ងៃ ការអប់រំអាកប្បកិរិយា និងរៀនពីរបៀបផលិតថង់ក្រដាស។